ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

លេខៈ ៤២៩៣៩៧ /គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មេសា ឆ្នាំ២០១៦

## ជម្រាបជូន
## លោកស្រីនាយិកាប្រតិបត្តិអង្គការបន្ទាយស្រី

**កម្មវត្ថុ** ៖ អំពីសំណើសុំការគាំទ្រ និងសម្របសម្រួលដល់អង្គការបន្ទាយស្រី ដើម្បីអនុវត្តកម្មវិធី “ ពង្រឹងអំណាចស្ត្រីជនបទនៅកម្ពុជា ដើម្បីនិរន្តរភាពសេដ្ឋកិច្ច និងកម្មវិធីស្ត្រីក្នុងវិស័យនយោបាយ ” នៅក្នុងខេត្តបាត់ដំបង និងខេត្តសៀមរាប។

**យោង** ៖ លិខិតរបស់អង្គការបន្ទាយស្រី ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៦។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោកស្រីនាយិកា ជ្រាបថា លេខាធិការដ្ឋាន គ.ជ.អ.ប យល់ព្រមអនុញ្ញាតឱ្យអង្គការបន្ទាយស្រី ដែលជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយធ្វើសកម្មភាពដើម្បីពង្រឹងសមត្ថភាពស្ត្រីក្នុងភាពជាអ្នកដឹកនាំគ្រប់លំដាប់ថ្នាក់ និងពង្រឹងការចូលរួមរបស់ស្ត្រីនៅក្នុងដំណើរការអភិវឌ្ឍន៍មូលដ្ឋាន លើកកម្ពស់សមភាពយេនឌ័រ និងសិទ្ធិស្ត្រី ព្រមទាំងបញ្ឈប់អំពើហិង្សាផ្អែកយេនឌ័រ នៅក្នុងឃុំ សង្កាត់គោលដៅមួយចំនួននៃក្រុងបាត់ដំបង ស្រុកបវេល ខេត្តបាត់ដំបង និងឃុំគោលដៅមួយចំនួននៃស្រុកអង្គរធំ ស្រុកពួក ខេត្តសៀមរាប ដោយអនុវត្តកម្មវិធីរបស់ខ្លួនចាប់ពីដើមឆ្នាំ២០១៦ រហូតដល់ដំណាច់ឆ្នាំ២០១៨ ខាងមុខនេះ។

ពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីទាំងពីរខាងលើនេះ អង្គការបន្ទាយស្រីត្រូវធ្វើកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋានក្នុងពេលអនុវត្តការងារជាក់ស្តែង និងត្រូវអនុវត្តសកម្មភាពស្របតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល លិខិតបទដ្ឋានគតិយុត្តនានាជាធរមាន និងលក្ខន្តិកៈរបស់ខ្លួនដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ។ ជាមួយគ្នានេះ រាល់ដំណាច់ឆ្នាំនីមួយៗ សូមលោកស្រីនាយិកាធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរស្តីពីលទ្ធផលនៃការអនុវត្តកម្មវិធីរបស់ខ្លួនជូនក្រសួងមហាផ្ទៃ។

អាស្រ័យហេតុនេះ សូមលោកស្រីជ្រាបជាព័ត៌មាន និងចាត់ចែងតាមការគួរ ។

សូមលោកស្រី ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

ជ. **ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**